# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 162

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

## ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : គម្រោងសាងសង់សាលាមធ្យមបច្ចេកទេស

២. កាលបរិច្ឆេទគម្រោង

កាលបរិច្ឆេទចាប់ផ្តើមគម្រោង 01/06/18

កាលបរិច្ឆេទបញ្ចប់គម្រោង 30/06/19

៣. ចំណាយគម្រោងសរុប $960,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងមហាផ្ទៃ

RESPONSIBLE UNIT

អង្គភាពទទួលខុសត្រូវ

៥. ស្ថានភាពគម្រោង គម្រោងដែលបានលុបចោល

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទាន៖ ថវិកាជាតិ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី១- ការពង្រឹង និងការកែទម្រង់ស្ថាប័ន

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

ការអនុវត្តគម្រោងនេះ សំដៅចូលរួមកសាងធនធានមនុស្សក្នុងជួរកងកម្លាំងនគរបាលជាតិ និងមន្ត្រីពន្ធនាគារ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងបរិបទរីកចំរើនរបស់ប្រទេសក្នុងតំបន់ និងលើសកលលោក។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ Technical and Vocational Education

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

កំពង់ស្ពឺ,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

គោលបំណងសំខាន់នៃគម្រោងនេះ គឺកសាងមូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធរូបវន្តរឹងមាំ សម្រាប់បម្រើការងារ បណ្តុះបណ្តាលជំនាញបច្ចេកទេសដល់កងកម្លាំងនគរបាលជាតិ និងមន្ត្រីពន្ធនាគារ ក្នុងក្របខណ្ឌវិជ្ជាជីវៈរបស់ខ្លួន សំដៅទទួលបានចំណេះដឹងបច្ចេកទេសថ្មីៗបន្ថែម ពាក់ព័ន្ធការងារជំនាញ។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

ការសាងសង់រួមមាន ៖

- អគារសិក្សា ១ខ្នងធ្វើពីបេតុង ជញ្ជាំងរៀបឥដ្ឋ ទំហំ (៤៥មx១៣ម) + (៥មx២ម) កំពស់ ៩,៦៥ម
- អគារស្នាក់នៅសិក្ខាកាម ២ខ្នង ធ្វើពីបេតុង ជញ្ជាំងរៀបឥដ្ឋ ទំហំ (១២មx៤០ម) កំពស់ ៨,៥០ម
- អគាររដ្ឋបាល ១ខ្នង ធ្វើពីបេតុង ជញ្ជាំងរៀបឥដ្ឋ ទំហំ (២៨មx១០ម)+(១០មx៦ម)+(៦មx៤ម) កំពស់ ៩,៦៥ម
- អគារស្នាក់នៅគ្រូ ១ខ្នង ធ្វើពីបេតុង ជញ្ជាំងរៀបឥដ្ឋ ទំហំ (៧,៥០មx២៨ម)+(៤មx១២ម)+(៥មx២ម) កំពស់ ៧,៤៨ម
- ផ្ទះដាំ និងហូបបាយ ១ខ្នង ធ្វើពីបេតុង ជញ្ជាំងរៀបឥដ្ឋ ទំហំ (១០មx២៥ម)+(១៥មx៥ម)+(៥មx២ម) កំពស់ ៨,៦៨ម
- បន្ទប់អនាម័យ ២ខ្នង (១ខ្នង=១០បន្ទប់) និងអាងស្តុកធ្វើអំពីបេតុង ជញ្ជាំងរៀបឥដ្ឋ
- បន្ទប់អនាម័យ ១ខ្នង= ៥បន្ទប់ និងអាងស្តុកធ្វើអំពីបេតុង ជញ្ជាំងរៀបឥដ្ឋ
- អាងងូតទឹក ១២អាង ធ្វើអំពីបេតុង ជញ្ជាំងរៀបឥដ្ឋ ទំហំ (៣មx១,២០ម) កំពស់ ១,៣០ម
- ប៉មទឹកចំណុះ ២០ម៉ែត្រគូប, អាងទឹកចំណុះ ១៥ម៉ែត្រគូប, អណ្តូងបុកទឹកស្អាត និងបណ្តាញទឹកស្អាត

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

ការអភិវឌ្ឍន៍សមត្ថភាព ចំណេះដឹង គឺជាកត្តាគន្លឹះក្នុងការធានានិរន្តរភាព និងប្រសិទ្ធភាពការងារ។ ប្រភពផ្តល់នូវចំណេះដឹង និងបទពិសោធន៍ គឺតាមរយៈការសិក្សា ការអាន និងទំនាក់ទំនងក្នុងសង្គម។ ដូច្នេះ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តសម្រាប់បម្រើការងារបណ្តុះបណ្តាលគឺមានភាពចាំបាច់ និងបង្ហាញឱ្យឃើញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលក្នុងវិស័យអប់រំ និងចូលរួមចំណែកលើកកម្ពស់កិត្យានុភាពរបស់ប្រទេសជាតិ។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

គម្រោងនេះ គឺបានផ្តល់ផលប្រយោជន៍ដោយផ្ទាល់ដល់មន្ត្រី បុគ្គលិកដែលបម្រើការងារនៅទីនោះ។ ចំពោះនិស្សិត សិក្ខាកាមជាមន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារ ដែលមកសិក្សានៅទីនេះ ទទួលប្រយោជន៍ដោយផ្ទាល់ក្នុងការស្នាក់នៅ សិក្សារៀនសូត្រ និងដោយប្រយោលគឺទទួលបានចំណេះដឹងថ្មីៗ ពីការសិក្សានៅទីនេះ។ នៅពេលមន្ត្រីរាជការប្រកបដោយចំណេះដឹង គោរពច្បាប់ ប្រជាពលរដ្ឋនិងទទួលបានសេវាកាន់តែល្អប្រសើរ ប្រទេសជាតិប្រកបដោយសន្តិសុខ សុវត្ថិភាព ស្ថេរភាព ដែលជាចលករជំរុញដល់ការអភិវឌ្ឍប្រទេស។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | គ្មាន |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | មិនទាន់ចាប់ផ្តើម |

១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

នៅពេលចាប់ដំណើរការសាងសង់ គម្រោងនេះនឹងជួយបង្កើតការងារដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ ក្រោយពេលគម្រោងបញ្ចប់ និងដាក់ឱ្យដំណើរការ វាជួយកាត់បន្ថយភាពក្រីក្រប្រជាពលរដ្ឋនៅតំបន់នេះ តាមរយៈការប្រកបអាជីវកម្មផ្សេងៗ ដែលជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ និងកាត់បន្ថយនូវការធ្វើចំណាកស្រុក។

១៩. ការប្រែប្រួល អាកាសធាតុ

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
| --- | --- | --- |

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**មិនមាន**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**មាន**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**មិនមាន**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

2

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

**មិនមាន**

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2021 | | 2022 | 2023 | 2024 | 2025 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2023-2025 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 350.0 | 610.0 | 0.0 | 960.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 350.0 | 610.0 | 0.0 | 960.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 350.0 | 610.0 | 0.0 | 960.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2021 | | 2022 | 2023 | 2024 | 2025 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2023-2025 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 0.0 | 0.0 | 0.0 | 350.0 | 610.0 | 0.0 | 960.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: